ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៧
ចុះថ្ងៃទី១៥-១១-២០០០
សាលដីកា
លេខ: ១២
ចុះថ្ងៃទី០៧-០៣-២០០១

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៧ខែមិនាឆ្នាំ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២ - លោក ឈឹម ស៊ីផល ចៅក្រម
៣ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៤ - លោក ទៀវល មួន ចៅក្រម
៥ - លោក ជីវ កេង ចៅក្រម

លោក ឃាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ទ័ប៉ន សារវឿន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខគ្មានលេខចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះ ថៃ ណាត និង ថៃ ណន ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១២០៦ ចុះថ្ងៃទី ១៩ - ៤ - ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ៦៧ ចុះថ្ងៃទី១៥-១១-២០០០ របស់តុលាការកំពូល ។

១ - ជនជាប់ចោទឈ្មោះ ថៃ ណាត "ម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនិងទីលំនៅសព្វថ្ងៃភូមិ ឃុំ រមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះតាំ ថៃ "ស" ម្តាយឈ្មោះដឹម ស្រី "រ" ប្រពន្ធឈ្មោះ ហៀង ថុល "ស" ទោសពីមុនគ្មាន ។ នៅក្នុងឃុំ ។

២ - ជនជាប់ចោទឈ្មោះ ថៃ ណន ភេទ ប្រុស អាយុ៣៧ ឆ្នាំ "ម្ចាស់បណ្តឹងសាទុក្ខ" ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនិងទីលំនៅសព្វថ្ងៃភូមិកណ្តាល ឃុំ ស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល ។ឪពុកឈ្មោះតាំ ថៃ "ស" ម្តាយឈ្មោះដឹម ស្រី "រ" ប្រពន្ធឈ្មោះ ផេ ផាត ទោសពីមុខគ្មាន នៅក្នុងឃុំ ។

- ត្រូវចោទពីបទៈ មនុស្សឃាតគិតទុកជាមុន

- មេធាវី អ្នកស្រីឃុន គឹមលន់

៣- ជនជាប់ចោទឈ្មោះទិណ ណឹម ភេទ ប្រុស អាយុ២៨ ឆ្នាំ ជាតិខ្មែរ កើត និងទីលំនៅមុនពេលចាប់ខ្លួនភូមិកណ្តាល ឃុំ ស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល ។ ឪពុកឈ្មោះតា ទិណ "ស" ម្តាយឈ្មោះជឹម ស្រី "រ" នៅលីវ ទោសពីមុនគ្មាន " គេចខ្លួន " ។

- ត្រូវចោទពីបទៈមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិកណ្តាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្ត កណ្តាល កាលពីថ្ងៃទី០៣-០១-៩៨ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោស តាមមាត្រា៣៥និង៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនរងគ្រោះឈ្មោះ ទាំ គ្មានសាវតាជាតិ " ស្លាប់ "

- មេធាវី គ្មាន

- តាមបណ្តឹងសាទុក្ខគ្មានលេខចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះទិណ ណាត និងទិណ ណន ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី១៩-៤-២០០០ របស់ សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- តាមអង្គហេតុកាលពីថ្ងៃទី០៣-០១-៩៨ ឈ្មោះទិណ ណាត ,ទិណ ណន ,ទិណ ណឹម និង ឈ្មោះមឿន បានរាបគំរោងដើម្បីសំលាប់មនុស្សឈ្មោះ ទាំ យកម៉ូតូមួយគ្រឿង អ្នកទាំង៤បានត្រៀមលួចចាក់កណ្តុរ កាំបិតខ្មែរ កាំបិតចិតបន្លែ ។ ចុះពេលល្ងាចអ្នកទាំង៤បបួលជនរងគ្រោះឈ្មោះ ទាំ ផឹកស្រា ពេលស្រវឹងក៏បបួលជនរងគ្រោះទៅចាក់កណ្តុរនៅបឹងស្វាយរមាស ស្រាប់តែឈ្មោះទាំង ៤ ព្រួតគ្នាវាយ ចាក់ជនរងគ្រោះបណ្តាលឱ្យស្លាប់ ហើយដោះយកសំភារៈមាននាឡិកា ចិញ្ចៀន ខ្សែក ហើយក៏អូសសាកសពដាក់ចូលក្នុងបឹងក្រោមកំប្លោក ឯម៉ូតូជនរងគ្រោះដែលទុកនៅផ្ទះទិណ ណឹម នោះត្រូវឈ្មោះទិណ ណឹម និងមឿន ជិះយកទៅបាត់ទៅ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្ត កណ្តាលសំរេច :

១- ចោទប្រកាន់លើឈ្មោះទិណ ណាត អាយុ ៤៧ ឆ្នាំ " ឃុំខ្លួន "

ឈ្មោះទិណ ណន អាយុ ៣៧ ឆ្នាំ " ឃុំខ្លួន "

ភូមិ កណ្តាល ឃុំ ស្វាយរមៀត ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល .

ឈ្មោះ ទិណ ណឹម អាយុ ២៨ ឆ្នាំ "គេចខ្លួន"

ពីបទៈ ប្លន់ និងសម្លាប់មនុស្ស នៅខេត្ត កណ្តាល

២- បង្អង់បណ្តឹងអាជ្ញាលើឈ្មោះមឿនអាយុ៣៧ឆ្នាំ " គេចខ្លួន " ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២២ "ព" ចុះថ្ងៃទី១៦-៦-៩៨របស់តុលាការខេត្ត កណ្តាលដែលបានសំរេចដូចតទៅ :

១- ផ្តន្ទាទោស :

- ឈ្មោះទិណ ណាត ភេទ ប្រុស អាយុ៤៧ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១២ ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២៦-០១-៩៨ ។

- ឈ្មោះទិណ ណន ភេទ ប្រុស អាយុ៣៧ ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ ឆ្នាំ គិតពី

ថ្ងៃឃុំខ្លួន ថ្ងៃទី២៦-០១-៩៨ ។

- ឈ្មោះ ចែណ ណើម ភេទប្រុស អាយុ២៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់១៨ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។

ពីបទៈ មនុស្សឃាតគិតទុកជាមុន កាលពីថ្ងៃទី០៣-០១-៩៨ នៅភូមិកណ្តាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៣៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- វត្ថុតាង មានដំបងឫស្សី១ ប្រវែង១ ,៧០ម. កូនកាំបិតចិតបន្លែ១ ខោអាវមួយចំនួន ត្រូវរឹបអូសបំផ្លាញចោល ។

៣- ទុកសិទ្ធិឱ្យគ្រួសារជនរងគ្រោះ ប្តឹងទាមទារសំណងជំងឺចិត្តពីជនជាប់ចោទទាំងពីរនាក់នេះបាន ។

៤- សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ចែណ ណាត , ចែណ ណន កំបាំងមុខជនជាប់ចោទឈ្មោះ ចែណ ណើម និងគ្រួសារជនរងគ្រោះ ។

បើកផ្លូវប្តឹងទាស់រយៈពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងនិងប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃផុតកំណត់ប្តឹងទាស់ចំពោះឈ្មោះ ចែណ ណើម និងគ្រួសារជនរងគ្រោះ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២-៧-៩៨ របស់ឈ្មោះ ចែណ ណាត , ចែណ ណន ដែលប្តឹងពីសាលក្រមព្រហ្មទណ្ឌលេខ២២ "ព" ចុះថ្ងៃទី១៦-៦-៩៨ របស់តុលាការខេត្ត កណ្តាល លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: សុំឱ្យតុលាការសំរេចតែម្តង ព្រោះការសួរដេញដោល គឺបានសួររួចហើយ កាលពីថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០០០ កន្លងមក ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី១៩-៤-២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២-៧-៩៨ របស់ឈ្មោះ ចែណ ណាត , ចែណ ណន ទុកជាត្រឹមត្រូវតាមទំរង់តែបដិសេធចោលដោយទាស់ខុសនិងគតិច្បាប់ ។

២- តំកល់សាលក្រមព្រហ្មទណ្ឌលេខ២២ "ព" ចុះថ្ងៃទី១៦-៦-៩៨ របស់តុលាការខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខមេធាវីអ៊ុកវ៉ាន់ដេត កំបាំងមុខជនជាប់ចោទបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខគ្មានលេខចុះថ្ងៃទី២៨ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះ ចែណ ណាត និង ចែណ ណន ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១០២ចុះថ្ងៃទី១៩-៤-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញលិខិតបញ្ជូនឱ្យធ្វើសារណាចុះថ្ងៃទី២៨-១១-២០០០ របស់តុលាការកំពូល

បង្គាប់អោយឈ្មោះ ទឹណ ណាត ទឹណ ណន ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួន ហើយឈ្មោះនេះបានទទួលនៅថ្ងៃទី២៨-១១-២០០០ រួចហើយ ប៉ុន្តែមិនបានធ្វើសារណាតាមកំណត់ច្បាប់ទេ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ទឹណ ណាត និង ទឹណ ណន ពីបទៈប្លន់និងធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិកណ្តាល ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣-០១-៩៨ ឡើយ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ទឹណ ណាត នាពេលសវនាការថា៖ បានជាខ្លួនប្តឹងសាទុក្ខមិនសុខចិត្តពីសាលដីកាសាលាឧទ្ធរណ៍ ព្រោះថា រឿងហេតុទាំងអស់ដែលកើតឡើងកាលពីថ្ងៃទី០៣-០១-៩៨ នោះខ្លួនពុំបានដឹងអ្វីឡើយ គឺខ្លួននៅផ្ទះមើលកូនចៅមិនដើរទៅណាទេ មានអ្នកជិតខាងនៅក្បែរផ្ទះបានដឹងឮដែរ សូមតុលាការកំពូលរកយុត្តិធម៌ឱ្យខ្លួនផង ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ទឹណ ណន នាពេលសវនាការថា៖ ខ្លួនមិនបានប្រព្រឹត្តអំពើមនុស្សឃាតក្នុងរឿងនោះទេ ឯអ្នកស្លាប់ក៏ខ្លួនមិនដែលស្គាល់ ហើយឈ្មោះ មឿន នោះក៏ខ្លួនពិតជាមិនស្គាល់ទៅទៀត ចំពោះឈ្មោះណើម ជាប្អូននោះពុំដែលទំនាក់ទំនងជាមួយខ្លួនដែរ ។ នៅពេលចាប់ខ្លួន គឺខ្លួននៅលើផ្ទះដែលរក្សាប្រពន្ធឆ្លងទន្លេ ឯផ្ទះ ទឹណ ណាត ក៏នៅឆ្ងាយពីផ្ទះខ្លួនដែរ សូមតុលាការរកយុត្តិធម៌ផង ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រីឃុត គឹមលន់ ការពារឱ្យជនជាប់ចោទ ឈ្មោះ ទឹណ ណាត និង ទឹណ ណន នាពេលសវនាការថា៖ តាមនីតិវិធីនៃរឿងព្រហ្មទណ្ឌការចាប់ខ្លួនឃុំខ្លួនគឺជាការប្រព្រឹត្តនិងកំពុងប្រព្រឹត្តជាក់ស្តែង ឯរឿងនេះការចាប់កូនក្តីរបស់ខ្លួនមានរយៈពេលរឿងហេតុរំលងជាង២០ថ្ងៃ ទើបនគរបាលព្រហ្មទណ្ឌចុះចាប់យកខ្លួនកូនក្តីខ្លួន ដែលស្ថិតនៅក្នុងផ្ទះទាំងអស់គ្នា ខុសនឹងនីតិវិធីអនុវត្តព្រហ្មទណ្ឌអន្តរកាល ។ ម្យ៉ាងទៀតការចាប់នោះគឺនៅពេលយប់ ឯភស្តុតាងគ្មានអ្វីទាំងអស់ យកចម្លើយតាមការធ្វើទារុណកម្មប៉ុណ្ណោះ បើពិនិត្យលើឈ្មោះណើម និងអ្នករងគ្រោះ ទើបមានទំនាក់ទំនងគ្នា ដោយឡែកឈ្មោះ ទឹណ ណាត និង ទឹណណន គ្រាន់តែបងប្អូនគ្នាទេ ពុំមានទាក់ទិនការប្រព្រឹត្តបទល្មើសឡើយ ។សូមតុលាការកំពូលលើកលែងចោទប្រកាន់កូនក្តីរបស់ខ្លួននិងសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងស្រុង ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា៖ ពុំមានមតិអ្វីទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋានរបស់ខ្លួនដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍.

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ.

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខគ្មានលេខចុះថ្ងៃទី២៨-៥-២០០០ របស់ឈ្មោះ ទឹណ ណាត និងឈ្មោះ ទឹណ ណន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤៥នៃ ច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចតុលាការខេត្ត កណ្តាលដែរ ដែលសំរេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ ទឹណ ណាត និងឈ្មោះ ទឹណ ណន ដាក់ពន្ធនាគារដោយអាងហេតុថា មានពិរុទ្ធភាពគ្រប់គ្រាន់ពីបទមនុស្សឃាតគិតទុកជាមុននោះ ពុំទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ពីព្រោះថា:

• ពុំមានភស្តុតាងណាមួយបញ្ជាក់អំពីសកម្មភាព ធ្វើឃាតទៅលើជនរងគ្រោះឡើយ ។

• ចម្លើយសាក្សីបក្លីពុំមានមូលដ្ឋានច្បាស់លាស់ឡើយពីព្រោះថា អំពើល្មើសកើតឡើងនៅពេលយប់ពីម៉ោង២០,០០ ទៅម៉ោង២៣,០០ ។

• វត្ថុតាងនៃអំពើល្មើសនិងសំលៀកបំពាក់របស់ជនរងគ្រោះដែលសមត្ថកិច្ចដកហូតបាននៅក្បែរសពនិងលើខ្លួនសព ពុំស្របនឹងចម្លើយរបស់សាក្សីឡើយ ។

• សពជនរងគ្រោះរលេះរលួយនៅសល់តែលលាដ៏ក្បាល ពុំមានភស្តុតាងច្បាស់លាស់បញ្ជាក់ថា ជាសពរបស់ឈ្មោះរាំ ដូចការអះអាងរបស់សាក្សីឡើយ ។

- យល់ឃើញថា បទល្មើសមនុស្សឃាតនេះពុំមានលក្ខណៈជាបទល្មើសជាក់ស្តែងឡើយ ហើយការតាមចាប់ខ្លួននិងការសួរយកចម្លើយជនជាប់ចោទ ធ្វើឡើងដោយខុសនីតិវិធី ។

- យល់ឃើញថា ដើម្បីអោយមានមូលដ្ឋានច្បាស់លាស់តុលាការអង្គសេចក្តីគប្បីធ្វើការស៊ើបអង្កេតបន្ថែមអំពីវត្តមានរបស់ជនជាប់ចោទពេលមានអំពើមនុស្សឃាតនិងទំនាក់ទំនងរបស់ជនជាប់ចោទជាមួយជនល្មើសដទៃទៀត ក៏ដូចជនរងគ្រោះដែរ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០២ ចុះថ្ងៃទី ១៩-៥-២០០ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី ចំពោះមុខ ជនជាប់ចោទ

១- ទទួលបណ្តឹងសាទុក្ខគ្មានលេខ ចុះថ្ងៃទី ២៨-៥-២០០០ របស់ឈ្មោះ ទឹណ ណាត និង ទឹណ ណន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១០២ ចុះថ្ងៃទី១៩-៤-២០០០ របស់សាលាឧទ្ធរណ៍ ។

៣ - បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៦៧ ចុះថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ

នៅថ្ងៃទី០៧ ខែមិនា ឆ្នាំ ២០០១